សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

# សារលិខិតស្វាគមន៍
# សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
# សម្រាប់បើកកិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍អេកម៉ិក (ACMECS) លើកទី៥
# និងកិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍ CLMV លើកទី៦
# ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២២ ខេត្តសៀមរាប

- *ឯកឧត្តម, លោកជំទាវ រដ្ឋមន្ត្រីនិងថ្នាក់ដឹកនាំទេសចរណ៍ អេកម៉ិក(ACMECS) និង CLMV*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ អន្តរជាតិ!*

តាងនាមឲ្យប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមសម្ដែងនូវការស្វាគមន៍យ៉ាងកក់ក្ដៅ ចំពោះវត្តមានរបស់គណៈប្រតិភូជាតិ-អន្តរជាតិ ដែលបានអញ្ជើញចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍យុទ្ធសាស្ត្រ កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាយ៉េយ៉ាវ៉ាឌី-ចៅប្រាយ៉ា-មេគង្គ (អេកម៉ិក) លើកទី៥ និងកិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍កម្ពុជា-ឡាវ-មីយ៉ាន់ម៉ា-វៀតណាម (CLMV) លើកទី៦ នាថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២២ នៅលើទឹកដីអង្គរ ខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា។

ប្រជាពលរដ្ឋកម្ពុជា ពិតជាមានមោទនភាព ដែលបានទទួលធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំអន្តរជាតិធំៗជាច្រើន បន្ទាប់ពីការប្រកាសបើកប្រទេសឡើងវិញ ចាប់ពីចុងឆ្នាំ២០២១ មក។ ម្យ៉ាងទៀត ដោយកម្ពុជា**មានភាពស៊ាំសហគមន៍** ក្រោម**នយោបាយកំណត់យកការចាក់វ៉ាក់សាំងជាគន្លឹះ** និងដោយប្រសិទ្ធភាពនៃការអនុវត្ត**ផែនទីចង្អុលផ្លូវស្ដីពីការស្ដារនិងលើកស្ទួយទេសចរណ៍កម្ពុជាអំឡុង និងក្រោយវិបត្តិកូវីដ-១៩ ២០២០-២០២៥** ផងនោះ ភ្ញៀវទេសចរអន្តរជាតិកាន់តែច្រើនឡើងបានមកទស្សនាកម្ពុជា ស្របពេលដែលភ្ញៀវទេសចរផ្ទៃក្នុងក៏មានចំនួនកើនឡើង គួរឲ្យកត់សម្គាល់ផងដែរ។

ខ្ញុំសូមឆ្លៀតឱកាសនេះអរគុណចំពោះបណ្ដាប្រទេសជាមិត្តទាំងអស់ ដែលតែងតែគាំទ្រដល់តួនាទីដ៏សំខាន់របស់កម្ពុជាក្នុងកិច្ចការងារតំបន់ និងអន្តរជាតិ ជាពិសេស ឆ្នាំ២០២២នេះ ក្នុងភាពជាប្រធានប្ដូរវេនអាស៊ាន កម្ពុជាត្រូវសម្របសម្រួលរកដំណោះស្រាយចំពោះបញ្ហាប្រឈមទាំងឡាយបង្កឡើងដោយវិបត្តិកូវីដ-១៩, បញ្ហាតំបន់, វិបត្តិនយោបាយនិងសេដ្ឋកិច្ចសកលលោកជាដើម ស្របតាមមូលបទ "**អាស៊ានរួមគ្នាធ្វើះដោះស្រាយបញ្ហាប្រឈមទាំងអស់គ្នា** (ASEAN A.C.T: Addressing Challenges Together)"។

កិច្ចប្រជុំខាងលើ ពិតជាបានបង្ហាញនូវសាមគ្គីភាពក្នុងតំបន់ ជាពិសេស ជាឱកាសដែលថ្នាក់ដឹកនាំទេសចរណ៍អេកម៉ិក និងCLMV ធ្វើការវាយតម្លៃផលប៉ះពាល់នៃវិបត្តិកូវីដ-១៩ មកលើវិស័យទេសចរណ៍ ដាក់ចុះយុទ្ធសាស្ត្រសមស្របក្នុងការស្ដារឡើងវិញ និងបង្កើនកិច្ចសហប្រតិបត្តិការថែមទៀត។ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំកន្លងមករបស់ថ្នាក់ដឹកនាំទេសចរណ៍អេកម៉ិក និងCLMV ដែលតាមរយៈកិច្ចប្រជុំ២ឆ្នាំម្ដង បានជំរុញឲ្យមានកំណើននៃលំហូរទេសចរវាងប្រទេសជាសមាជិក ក៏ដូចជាកិច្ចសហការផ្សព្វផ្សាយទាក់ទាញទេសចរពីប្រទេសទីបី បានយ៉ាងមានប្រសិទ្ធភាព ក្រោមយុទ្ធនាការ "**ប្រទេស ៥ គោលដៅទេសចរណ៍តែមួយ**" និង "**ប្រទេស ៤ គោលដៅទេសចរណ៍តែមួយ**"។

ពិតណាស់ថា ឆ្លងកាត់វិបត្តិកូវីដ-១៩ រយៈពេល ២ឆ្នាំ កន្លងមកនេះ តួនាទីនៃវិស័យទេសចរណ៍ត្រូវបានមើលឃើញ កាន់តែចំបាច់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច និងភាពរីកចម្រើនរបស់សង្គមជាតិ ហើយជាពិសេសតួនាទីដ៏សំខាន់ក្នុងការពង្រឹងទំនាក់ទំនងរវាងប្រជាជាតិនិងប្រជាជាតិ, សាមគ្គីភាព និងមិត្តភាពនៃប្រទេសក្នុងតំបន់។ ក្នុងន័យនេះ ជាមូលដ្ឋាននៃការអភិវឌ្ឍវិស័យទេសចរណ៍អេកម៉ិក និង CLMV ទាំងពេលបច្ចុប្បន្ន និងអនាគត ខ្ញុំសូមចែករំលែកនូវការគិតគូរមួយចំនួន ដល់កិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍ ដូចតទៅ៖

**ទី១.** អេកម៉ិក និង CLMV គួរបង្កើនកិច្ចសហប្រតិបត្តិការលើការអភិវឌ្ឍផលិតផលថ្មីៗ បំពេញឲ្យគ្នាទៅវិញទៅមក និងផ្តល់នូវភាពសំបូរបែបដល់ទេសចរ ស្របតាមការប្រែប្រួលនិន្នាការទេសចរណ៍ក្រោយវិបត្តិកូវីដ-១៩។ ក្នុងន័យនេះ ប្រទេសសមាជិក គួរបង្កើនកិច្ចសហការលើការអភិវឌ្ឍទេសចរណ៍ជនបទ ដែលរួមមានទេសចរណ៍សហគមន៍, អេកូទេសចរណ៍, ទេសចរណ៍ផ្សងព្រេង, កសិទេសចរណ៍, ទេសចរណ៍សុខុមាលភាព, ទេសចរណ៍ម្ហូបអាហារ ជាដើម ដែលទាំងនេះ ជាតម្រូវការទេសចរណ៍កំពុងកើនឡើង ហើយចូលរួមដោយផ្ទាល់ដល់ការរីកចម្រើននៅមូលដ្ឋាន។ ទន្ទឹមនឹងនេះផងដែរ អេកម៉ិក និង CLMV គួរដាក់ចេញនូវក្របខណ្ឌកិច្ចសហប្រតិបត្តិការជួយគាំទ្រសហគ្រាសធនតូចបំផុត, តូច និង មធ្យម (MSMEs) ឲ្យក្លាយជា ឆ្អឹងខ្នងនៃការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយភាពធន់ និងចីរភាព។

**ទី២.** ក្នុងបរិបទឌីជីថលូបនីយកម្ម ប្រទេសអេកម៉ិក និង CLMV គួរជំរុញការផ្លាស់ប្តូរបទពិសោធន៍ លើដំណើរការបរិវត្តកម្មឌីជីថលក្នុងវិស័យទេសចរណ៍ ក្នុងនោះគួរដកពិសោធន៍គ្នាទៅវិញ ទៅមកលើការអនុវត្តកម្មវិធីអក្ខរកម្មឌីជីថលក្នុងវិស័យទេសចរណ៍ ការអភិវឌ្ឍជំនាញឌីជីថល ក៏ដូចជាការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ក្នុងការបង្កើនផលិតភាព និងឧត្តមភាពប្រកួតប្រជែង។

**ទី៣.** អេកម៉ិក និងCLMV គួរគិតគូរជំរុញលំហូរទេសចរផ្ទៃក្នុងតំបន់អាម៉ិក (ACMECS-Intra Traveler) និង លំហូរទេសចរផ្ទៃក្នុងតំបន់ CLMV (CLMV-Intra Traveler) ដោយត្រូវគិតគូរផងដែរ លើការបង្កើនការតភ្ជាប់ផ្លូវគោក ផ្លូវអាកាស និងផ្លូវទឹក បន្ថែមទៀត ព្រមទាំងជំរុញទេសចរណ៍បើកបរដោយខ្លួនឯង (Self-Driving Tour)។ សម្រាប់ការទាក់ទាញទេសចរពីប្រទេសទី៣ ខ្ញុំសូមគាំទ្រឲ្យបន្តផ្សព្វផ្សាយក្រោមយុទ្ធនាការ "**ប្រទេសប្រាំ គោលដៅទេសចរណ៍តែមួយ**" និង "**ប្រទេសបួន គោលដៅទេសចរណ៍តែមួយ**"។

**ទី៤.** ដើម្បីសម្របសម្រួលការអនុវត្តផែនការសកម្មភាពទេសចរណ៍អេកម៉ិក និង CLMV ដែលបានដាក់ចុះ ខ្ញុំសូមគាំទ្រនូវការគិតគូរបង្កើតឲ្យមានយន្តការស្ថាប័នទេសចរណ៍អេកម៉ិក និង CLMV ដែលអាចជាលេខាធិការដ្ឋាន ឬរចនាសម្ព័ន្ធណាមួយ ហើយកម្ពុជាមានសេចក្តីរីករាយក្នុងការទទួលធ្វើជាម្ចាស់ផ្ទះ។

– *ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!*

ជាទីបញ្ចប់ ខ្ញុំសូមជូនពរឲ្យកិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍អេកម៉ិកលើកទី៥ និងកិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍ CLMV លើកទី៦ នាថ្ងៃនេះ សម្រេចបានជោគជ័យខ្ពស់ និងសូមជូនពរឲ្យការស្នាក់នៅរបស់ប្រតិភូជាតិ និងអន្តរជាតិទាំងអស់ លើទឹកដីអង្គរ បានសេចក្តីសប្បាយរីករាយ និងការចងចាំល្អៗ។

ថ្ងៃ ចន្ទ ៧ រោច ខែ អស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០២២

**ហ៊ុន សែន**